00752838



**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 16-Nov-2011, 08:31
CMS/CFO: Phok Chanthan

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក (០៨)

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះតុលាការកំពូល សម្ងាត់/Confidential

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន: សាធារណៈ / Public

ឈ្មោះមន្ត្រីកត់ត្រា: Peang Tola 31/01/2012

ហត្ថលេខា:

---

**ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខផ្សេងៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ**

---

<u>ដាក់ដោយ</u>៖

**ក្រុមមេធាវីរបស់លោក នួន ជា៖**

សុន អារុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រំ ផល្លា

Zara LOCKSHIN

<u>ផ្ញើជូន</u>៖

**ជនជាប់ចោទដទៃទៀត**

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

Mojan SAMADI

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

## I. សេចក្តីផ្តើម

១. ក្រុមមេធាវីការពារក្តីជនជាប់ នួន ជា ("មេធាវីការពារក្តី") សូមដាក់ការឆ្លើយតបទៅនឹង"ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ" ("ចម្លើយតប")[១]។ ជាបញ្ហាបឋម មេធាវីការពារក្តីសូមប្រកាន់គោលជំហរថា ការឆ្លើយតបនេះគួរត្រូវបានចាត់ចំណាត់ថ្នាក់ជាឯកសារសាធារណៈ[២]។ នៅក្នុងកាលៈទេសៈណាក៏ដោយ មេធាវីការពារក្តីនឹងចាត់ទុកឯកសារនេះជាឯកសារសាធារណៈ។

## II. សារណាឆ្លើយតប

### ក. ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាទាក់ទិននឹងការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការពិចារណាទៅលើអង្គហេតុពាក់ព័ន្ធក្នុងការសម្រេចលើសំណើអនុលោមតាមវិធាន ៣៥ មិនមែនជាការស្មោះត្រង់ទេ

២. នៅចំណុចជាច្រើនក្នុងចម្លើយតប ការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") បានលើកឡើងថា ដោយសារអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា អំណះអំណាងនៃអង្គហេតុទាក់ទិននឹងការជ្រៀតជ្រែកផ្នែកនយោបាយ មិនអាចទទួលយកបាន ទាក់ទិននឹងអញ្ញត្រកម្មមួយក្នុងចំណោមអញ្ញត្រកម្មនានាដែលបានដាក់អនុលោមតាមវិធាន ៨៩ អង្គជំនុំជម្រះសាលាដំបូងមិនគួរ "ពិចារណាសាជាថ្មីឡើងវិញ" ទៅលើអំណះអំណាងនៃអង្គហេតុទាក់ទិននឹង "សំណើរបស់លោក នួន ជា សុំបំពេញ

---

[១] ឯកសារលេខ **E116/1/4**, ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១, លេខ ERN 00750799–00750816។

[២] *កំណត់សម្គាល់ពិសេស៖* ឯកសារនេះ រួមជាមួយនឹងបណ្តឹងសាទុក្ខ (ឯកសារលេខ **E116/1/1** "បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ" ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១, លេខ ERN 00746636–00746658 ("បណ្តឹងសាទុក្ខ")) ពុំមានភ័ស្តុតាងណាមួយដែលមិនទាន់ក្លាយជាកម្មវត្ថុនៃការផ្សព្វផ្សាយយ៉ាងច្រើនរបស់បណ្តាញសារព័ត៌មានទេ។ ដោយសារតែសារៈសំខាន់ទាំងផ្នែកស្ថាប័នផង និងសម្រាប់សាធារណជនផង ចំពោះបញ្ហានានាដែលបានលើកឡើងមកនោះ ការចាត់ទុកករណីនេះជាការសម្ងាត់នឹងក្លាយជាឧបសគ្គដល់កិច្ចដំណើរការនីតិវិធីដែលត្រឹមត្រូវ និងមានតម្លាភាព។ តាមពិត ការផ្សព្វផ្សាយជាសាធារណៈនឹងទំនងជាជួយកាត់បន្ថយនូវការជ្រៀតជ្រែកផ្នែកនយោបាយមិនត្រឹមត្រូវ។

កិច្ចស៊ើបសួរ អនុលោមតាមវិធាន ៣៥" ("សំណើអនុលោមតាមវិធាន ៣៥")[៣] ទេ។ គោលជំហរដដែលៗនេះ[៤] ដែលជាវិការៈចម្បងនៅក្នុងចម្លើយតប ទំនងជាធ្វើឱ្យមានភាពស្រពិចស្រពិលចំពោះការពិតជាមូលដ្ឋានមួយដែលថា៖ វិធាន ៨៩ និង វិធាន ៣៥ ជាបញ្ញត្តិពីរខុសគ្នាទាំងស្រុង។ វិធានទាំងពីរនេះដោះស្រាយបញ្ហាពីរផ្សេងគ្នារួមគ្នា បញ្ជាក់ពីលក្ខណៈវិនិច្ឆ័យដោយឡែក និងអនុញ្ញាតទម្រង់សំណូមពរផ្សេងៗពីគ្នា។ ដោយគ្រាន់តែអង្គជំនុំជម្រះសាលាដំបូងជ្រើសរើស (ប្រហែលពុំមានភាពត្រឹមត្រូវ) សម្រេចលើពាក្យសុំជាច្រើនរបស់មេធាវីការពារក្តីនៅក្នុងឯកសារតែមួយ មិនអនុញ្ញាតឱ្យចៅក្រមមិនអើពើចំពោះអង្គហេតុពាក់ព័ន្ធឡើយ ព្រោះថាអង្គហេតុទាំងនោះអនុវត្តចំពោះបញ្ហាអង្គច្បាប់ផ្សេងៗដែលបានលើកឡើង ដែលជាអ្វីដែលអង្គជំនុំជម្រះសាលាដំបូងធ្លាប់បានអនុវត្តកន្លងមក ដូចដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខស្រាប់[៥]។ ដោយពិតជាមិនបាន "អនុវត្តដោយត្រឹមត្រូវនូវឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីជាផលប្រយោជន៍ដល់ការសន្សំសំចៃថវិកា និង

---

[៣] ឯកសារលេខ **E82** "សំណើរបស់លោក នួន ជា សុំបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៣៥" ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១ លេខ ERN 00680941–00680955។

[៤] *សូមមើល* ចម្លើយតប, កថាខណ្ឌ ១១ ("អង្គជំនុំជម្រះសាលាដំបូងបានបន្តធ្វើតទៅទៀតបន្ទាប់ពីកថាខណ្ឌទាំងពីរនៃការវែកញែកហេតុផលដោយលម្អិតនេះ ដើម្បីរកឱ្យឃើញនូវផ្នែកទាំងឡាយនៅក្នុងអញ្ញត្រកម្មបឋមរបស់មេធាវី ដែលជាប់ទាក់ទងនឹង "ការជ្រៀតជ្រែកនៅក្នុងកិច្ចគ្រប់គ្រងរដ្ឋបាលរបស់តុលាការ" ដែលមិនអាចទទួលយកបាននេះ។ ហេតុដូចនេះទឡ្ហីករណ៍ទីមួយនៃការប្តឹងឧទ្ធរណ៍ត្រូវអាស្រ័យទាំងស្រុងទៅលើមូលដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមិនបាន*ពិនិត្យពិចារណាឡើងវិញ* លើការចោទប្រកាន់ទាំងពីរស្តីពីការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានពិនិត្យពិចារណា និងសម្រេចរួចហើយថា មិនអាចទទួលយកបានទេ កាលពីពេលសម្រេចបញ្ចប់លើសំណើសុំលើកទីមួយនេះ") កថាខណ្ឌ ២៨ ("ដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី ១១ ខាងលើស្រាប់ សេចក្តីសម្រេចដែលកំពុងតវ៉ាបានសម្រេចបញ្ចប់ (disposes) នូវការពោលអះអាង (claims) ជាក់លាក់ចំនួនពីររបស់មេធាវីការពារក្តី អំពីការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងសំណុំរឿង ០០២ ដោយយោងទៅលើអញ្ញត្រកម្មបឋម ដែលនៅក្នុងនោះការពោលអះអាងទាំងនេះត្រូវបានលើកឡើងកាលពីដើមដំបូង ហើយមិនមែននៅក្នុងសំណើសុំលើកទីមួយ ដែលការអះអាងដូចគ្នានេះត្រូវបានលើកឡើងដដែលៗនោះទេ" និងកថាខណ្ឌ ៣៨ ("សេចក្តីសម្រេចដែលកំពុងតវ៉ានេះអាចបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាអំពីខ្លឹមសារ និងទឡ្ហីករណ៍ទាំងអស់នៅក្នុងសំណើលើកទីមួយមុននឹងសម្រេចបញ្ចប់សំណើនោះ រួមទាំងការលើកឡើងចោទប្រកាន់ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ និង ០០៤ ផង។ ដោយឡែក អង្គជំនុំជម្រះសាលាដំបូងបានសង្ខេបបញ្ជីរឿងនៃសំណើលើកទីមួយ ហើយបានពិចារណាលើការលើកឡើងចោទប្រកាន់នៅក្នុងសំណើលើកទីមួយ ដើម្បីផ្ទុះបញ្ចាំងពីការលើកឡើងចោទប្រកាន់ទាំងនោះនៅក្នុងអញ្ញត្រកម្មរបស់មេធាវីការពារក្តី")។

[៥] *សូមមើល* បណ្តឹងសាទុក្ខ, កថាខណ្ឌ ១២, ២៤។

ប្រសិទ្ធភាពមិនមែនដើម្បីសម្រេចបញ្ចប់សាជាថ្មីម្តងទៀត លើការពោលអះអាងដដែលនៅពេលធ្វើការវាយតម្លៃលើសំណើ [តាមវិធាន ៣៥]"[៦] ដូចដែលគេអាចសន្និដ្ឋានជាមុនដែរគឺថា អង្គជំនុំជម្រះច្បាស់ជាពុំបានអើពើចំពោះអង្គហេតុនានាដែលបានដាក់ជូន ដើម្បីឱ្យអង្គជំនុំជម្រះអាចឈានទៅដល់លទ្ធផលមួយដែលបានកំណត់ទុកជាមុន[៧]។ ការសម្រេចដោយលឿនបែបនេះមិន "ស្រប" ឬមិន "លើសពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់នៃចំណុចចាប់ផ្តើម ដើម្បីឱ្យសេចក្តីសម្រេចមានការបញ្ជាក់ហេតុផលត្រឹមត្រូវ"[៨]។

**ខ. ក.ស.ព ប្រឹងប្រែង តែទីបំផុតខកខានមិនអាចធ្វើឱ្យទន្ទ្រានករណីសំខាន់នៃបណ្តឹងឧទ្ធរណ៍ចុះខ្សោយ**

៣. ដោយមានអំណះអំណាងតិចតួច មិនត្រឹមត្រូវតាមបច្ចេកទេស ហើយជាញឹកញាប់មិនចំចំណុចតែម្តង ចម្លើយតបនេះហាក់ដូចជារៀបចំដើម្បីធ្វើឱ្យបណ្តឹងសាទុក្ខទទួលបានបរាជ័យ ដោយប្រើការវាយប្រហារជាច្រើន តែគ្មានការវាយប្រហារណាមួយដែលអាចវាយប្រហារបានគ្រប់គ្រាន់ចំពោះចំណុចសំខាន់នៃបញ្ហាឡើយ។ ខាងក្រោមនេះជាឧទាហរណ៍ចំនួនបីដែលបង្ហាញពីវិធីសាស្ត្រទូទៅរបស់សហព្រះរាជអាជ្ញា៖

ក. ចម្លើយតបបានលើកឡើងថា បណ្តឹងសាទុក្ខ "បរាជ័យមិនបានបំពេញទៅតាមលក្ខខណ្ឌនៃភាពជាក់លាក់"[៩] ដោយសារថា ក្នុងចំណោមបញ្ហាដទៃទៀត បណ្តឹងសាទុក្ខបានយោងទៅដល់អំណះអំណាងអង្គហេតុដែលបានដាក់ពីមុនៗ[១០]។ មានតែអ្នកដែលបានធ្វើមិនដឹងមិនឮដោយចេតនាចំពោះការជ្រៀតជ្រែកផ្នែកនយោបាយនៅ អ.វ.ត.ក តែប៉ុណ្ណោះ ដែលទំនងជាមានច្រើននាពេលបច្ចុប្បន្នទេ ទើបខកខានមិនបានដឹងពីភាពជាក់លាក់នៃករណីដែលកំពុងពិភាក្សានេះ ដែលមានរៀបរាប់យ៉ាងច្បាស់ពីកថាខណ្ឌ ២ ដល់ កថាខណ្ឌ ១០ នៃបណ្តឹងសាទុក្ខ។ ជាងនេះទៀត ដូចដែលបានកត់សម្គាល់ និងបង្ហាញជាភស្តុតាងនៅក្នុងបណ្តឹង

---

៦ ចម្លើយតប, កថាខណ្ឌ ២៨។

៧ *សូមមើល ជាឧទាហរណ៍* បណ្តឹងសាទុក្ខ, កថាខណ្ឌ ២៨។

៨ ចម្លើយតប, កថាខណ្ឌ ២៨។

៩ ចម្លើយតប, កថាខណ្ឌ ១៦។

១០ *សូមមើល* ចម្លើយតប, កថាខណ្ឌ ១០។

សាទុក្ខរួចមកហើយ បណ្ដឹងសាទុក្ខនេះស្របទៅតាមលក្ខខណ្ឌតម្រូវបច្ចេកទេសនៃវិធាន ១០៤ វិធាន ១០៥ និង វិធាន ១០៩ ហើយ[១១]។ អាស្រ័យហេតុនេះ បណ្ដឹងសាទុក្ខនេះទទួលយកបាន*យ៉ាងពេញលេញ*។

ខ. ផ្ទុយពីការអះអាងរបស់ ក.ស.ព មេធាវីការពារក្ដីពិតជា "បានអះអាងពឹងផ្អែកលើអំណាចរបស់អង្គជំនុំជម្រះដើម្បីពិនិត្យមើលភ័ស្តុតាងដោយខ្លួនឯង" អនុលោមទៅតាមវិធាន ១០៤ (១)[១២]។ បណ្ដឹងសាទុក្ខពិតជាបានដកស្រង់វិធាននេះយ៉ាងច្បាស់លាស់[១៣]។ ជាងនេះទៀត ដូចចម្លើយតបបានកត់សម្គាល់យ៉ាងច្បាស់ *ភ័ស្តុតាងថ្មី* ត្រូវបានយោងក្នុង "កថាខណ្ឌចំនួនប្រាំស្ដីពីការអះអាងពីអង្គហេតុនៅដើមដំបូងនៃបណ្ដឹងសាទុក្ខ"[១៤]។ ចំពោះថាតើភ័ស្តុតាងទាំងនេះត្រូវបាន ឬមិនត្រូវបានចុះបញ្ជីនៅក្នុងតារាងមួយ ឬឧបសម្ព័ន្ធ[១៥] នោះ វាមិនសំខាន់ចំពោះអ្នកដែលមិនគិតគូរអំពីកំហុសតូចតាចៗ *(de minimis)* នៅក្នុងបញ្ញត្តិនៃ "សេចក្ដីណែនាំអនុវត្ត៦.៥"[១៦]ឡើយ។ ភាគីនានាអាចរកបាន និងប្រើប្រាស់បានយ៉ាងងាយនូវភ័ស្តុតាងដែលបានដកស្រង់នៅក្នុងជើងទំព័រនៃបណ្ដឹងសាទុក្ខសម្រាប់យកមកពិនិត្យ និងធ្វើវិភាគ ព្រោះថាមេធាវីការពារក្ដីបានស្នើសុំឱ្យអង្គជំនុំជម្រះឱ្យធ្វើដូច្នេះ។ ហើយបើទោះជាអង្គជំនុំជម្រះសាលាដំបូងមិនអាចត្រូវបានគេដាក់កំហុសដោយសារការខកខានមិនបានពិចារណាទៅលើអង្គហេតុដែលមិនត្រូវបានដាក់មកអង្គជំនុំជម្រះនោះ (ដោយហេតុថា ព្រឹត្តិការណ៍ទាំងនេះមិនទាន់បានកើតឡើងទេ)[១៧] អង្គជំនុំជម្រះ*នេះ* គួរតែពឹងផ្អែកលើភ័ស្តុតាងថ្មីៗ

---

[១១] *សូមមើល* ចម្លើយតប, កថាខណ្ឌ ២៣។

[១២] ចម្លើយតប, កថាខណ្ឌ ៣៩។

[១៣] *សូមមើល* បណ្ដឹងសាទុក្ខ, កថាខណ្ឌ ២០ ("សម្រាប់គោលបំណងទាំងអស់នេះ អង្គជំនុំជម្រះតុលាការកំពូលអាចបើកការពិនិត្យលើភ័ស្តុតាង និងស្វែងរកភ័ស្តុតាងថ្មី ដើម្បីធ្វើការសម្រេចលើបញ្ហានេះ")។

[១៤] ចម្លើយតប, កថាខណ្ឌ ៣៩។

[១៥] ចម្លើយតប, កថាខណ្ឌ ៣៩។

[១៦] ចម្លើយតប, កថាខណ្ឌ ៣៩។

[១៧] *សូមមើល* ចម្លើយតប, កថាខណ្ឌ ៣៩ (ដែលបានសន្និដ្ឋានថា "អង្គជំនុំជម្រះគួរតែកុំយកចិត្តទុកដាក់នឹងការអះអាងលើអង្គហេតុពាក់ព័ន្ធនឹងព្រឹត្តិការណ៍ដែលកើតឡើងក្រោយកាលបរិច្ឆេទ នៃដីកាសម្រេចដែលកំពុងតវ៉ា នៅពេលដែលអនុវត្តអំណាចរបស់ខ្លួនក្នុងការពិនិត្យសារជាថ្មីឡើងវិញខាងឧទ្ធរណ៍នេះ")។

ទាំងនេះ ក្នុងការសម្រេចថាតើ គួរ ឬមិនគួរចាត់វិធានវិជ្ជមាន អនុលោមតាមវិធាន ៣៥ ជាដំណើរការមួយដែល ក.ស.ព ខ្លួនឯងមិនអាចគាំទ្របាន។

គ. ការដែល ក.ស.ព លើកឡើងថា អង្គជំនុំជម្រះនេះពុំមានអំណាចក្នុងការយល់ព្រមតាមសំណូមពរដែលបានស្នើឡើងដោយមេធាវីការពារក្ដី ពោលគឺ *បង្គាប់*ឱ្យមានកិច្ចស៊ើបសួរមួយប្រកបដោយឯករាជ្យនោះ[១៨] ក.ស.ព ទំនងជាកាន់តែធ្វើឱ្យស្ថាប័នដែលទន់ខ្សោយនេះកាន់តែមានភាពទន់ខ្សោយថែមទៀតតែប៉ុណ្ណោះ។ បើតាមទស្សនៈរបស់សហព្រះរាជអាជ្ញា វិការៈដែលតម្រូវឱ្យសរសេរមួយកថាខណ្ឌតែម្ដងនោះគឺការដែលមេធាវីការពារក្ដីប្រើពាក្យថា "បង្គាប់" គឺខុសទៅនឹងពាក្យពេចន៍ដែលមានចែងច្បាស់នៅក្នុងវិធាន ៣៥ ដែលផ្ដល់អំណាចឱ្យអង្គជំនុំជម្រះនេះ "*បញ្ជូន* [ឧទាហរណ៍ស្ដីពីការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ] ទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ឬ អង្គការសហប្រជាជាតិ"[១៩]។ ជាការងាយយល់ អ្វីដែលមេធាវីការពារក្ដីចង់បាននោះគឺសេចក្ដីណែនាំរបស់តុលាការ (ដែលជាទូទៅ នៅក្នុងរង្វង់តុលាការគេហៅថា ដីកាបង្គាប់) ដែលបញ្ជូនបញ្ហានេះទៅឱ្យស្ថាប័នស៊ើបអង្កេតណាមួយដែលមានឯករាជភាព។ ការពិត ដំណោះស្រាយបែបនេះគឺស្ថិតក្នុងសមត្ថកិច្ចផ្ទាល់របស់អង្គជំនុំជម្រះនេះតែម្ដង។

អំណះអំណាងពាក់ព័ន្ធនឹងការចោទប្រកាន់ធ្ងន់ធ្ងរ និងអស់រយៈពេលជាយូរនៃការជ្រៀតជ្រែកផ្នែកនយោបាយនៅ អ.វ.ត.ក មិនមានហេតុផល និងធ្វើឱ្យមិនចំចំណុចសំខាន់នៃបណ្ដឹងសាទុក្ខ។

៤. ដូចអង្គជំនុំជម្រះសាលាដំបូងដែរ នាពេលនេះ ក.ស.ព បានចូលរួមជាមួយអ្នកដែលមានបំណងទទួលយកការដែលតុលាការនេះទំនងមិនអាចជៀសពីការផ្ដល់យុត្តិធម៌ក្នុងកម្រិតនៅក្រោម

---

[១៨] *សូមមើល* ចម្លើយតប, កថាខណ្ឌ ៤០ (ដែលបានកត់សម្គាល់ថា "មិនមានមូលដ្ឋានណាមួយតាមវិធាន ៣៥ សម្រាប់ឱ្យអង្គជំនុំជម្រះ [តុលាការកំពូល] "បង្គាប់" ដល់អង្គភាពតុលាការខាងក្រៅឱ្យដឹកនាំធ្វើការស៊ើបសួរតាមវិធាន ៣៥ នោះឡើយ")។

[១៩] វិធាន ៣៥(២)(គ) (គូសបញ្ជាក់បន្ថែម)។

"បទដ្ឋាន"[២០]។ ជាជាង គាំទ្រដល់ការអំពាវនាវដែលសមហេតុផល និងមានសំអាងហេតុត្រឹមត្រូវឱ្យមានការស៊ើបអង្កេតដែលបានលើកឡើងយូរហើយនោះ ក.ស.ព បែរជាចង់ពិនិត្យទៅលើបញ្ហាបន្ទាប់បន្សំទៅវិញ។ ពុំមានទទ្បីករណ៍បច្ចេកទេសណាមួយនៅក្នុងចម្លើយតប រារាំងអង្គជំនុំជម្រះមិនឱ្យទទួលយកសំណូមពរសំខាន់ដែលបានស្នើឡើងក្នុងបណ្តឹងសាទុក្ខនេះទេ ពោលគឺ៖ ការស៊ើបអង្កេតប្រកបដោយឯករាជ្យ។ ក្នុងអំណះអំណាងដែលមានកម្រាស់ ១៨ ទំព័រនោះ ពុំមានផ្តល់សំអាងហេតុណាមួយសម្រាប់ច្រានចោលជម្រើសនេះទេ។

## គ. មេធាវីការពារក្តីបានត្រៀមខ្លួនរួចជាស្រេចក្នុងការសហការនូវរាល់វិធាននានាដែលអង្គជំនុំជម្រះយល់ថាជាការសមរម្យ អនុលោមតាមវិធាន ៣៥

៥. មេធាវីការពារក្តីយល់ស្របជាមួយ ក.ស.ព ដែលថា "នៅពេលដែលបានទទួលបណ្តឹងសាទុក្ខនេះ [...] អង្គជំនុំជម្រះ[តុលាការកំពូល] មានសមត្ថកិច្ចបន្ថែមចាំបាច់ក្នុងការចាត់វិធានការសមស្របមួយចំនួន ដើម្បីលើកស្ទួយ និងគាំទ្រដល់សុចរិតនៃដំណើរការនីតិវិធីស៊ើបសួរ"[២១]។ ទាក់ទិននឹងបញ្ហានេះ "សហព្រះរាជអាជ្ញាបានសង្កេតឃើញថា បណ្តឹងសាទុក្ខ និងខ្លឹមសាររបស់វា ទំនងជាមានលេចចេញទៅ [...] អ្នកទទួល (ឯកសារ) ដែលមិនបានអនុញ្ញាត"[២២] ហើយ អាស្រ័យហេតុនេះ អង្គជំនុំជម្រះនេះគួរ "ចាត់វិធានការណាមួយក៏ដោយដែលអង្គជំនុំជម្រះយល់ឃើញថាសមស្រប ដើម្បីគាំទ្រដល់សុចរិតនៃកិច្ចដំណើរការនីតិវិធីស៊ើបសួរ"[២៣]។

៦. ទោះបីមានបញ្ជាក់យ៉ាងច្បាស់នៅក្នុងកថាខណ្ឌដំបូងនៃបណ្តឹងសាទុក្ខដែលថា មេធាវីការពារក្តីមានបំណងចាត់ទុកឯកសារនេះជាឯកសារសាធារណៈក៏ដោយ[២៤] តែដើម្បីជាការបញ្ជាក់ឱ្យបានច្បាស់ និងដើម្បីចៀសនូវរាល់ការមន្ទិលនានា មេធាវីការពារក្តីសូមជូនដំណឹងដល់អង្គជំនុំជម្រះថា

---

[២០] *សូមមើលជាឧទាហរណ៍* បណ្តឹងសាទុក្ខ, កថាខណ្ឌ ៦ (ដែលបានដកស្រង់ពី Mark Ellis, *International Bar Association*, 'Safeguarding Judicial Independence in Mixed Tribunals: Lessons from the ECCC and Best Practices for the Future', ខែ កញ្ញា ឆ្នាំ ២០១១)។

[២១] ចម្លើយតប, កថាខណ្ឌ ៤១។

[២២] ចម្លើយតប, កថាខណ្ឌ ៤៣។

[២៣] ចម្លើយតប, កថាខណ្ឌ ៤៥(គ)។

[២៤] *សូមមើល* បណ្តឹងសាទុក្ខ, កថាខណ្ឌ ១ ជើងទំព័រ ៤។

មេធាវីការពារក្ដីបានចាត់ទុកថាឯកសារនេះជាឯកសារសាធារណៈរួចហើយ។ ឯកសារចម្លងនៃបណ្ដឹងសាទុក្ខនេះត្រូវបានចែកចាយជាសាធារណៈទៅដល់សារព័ត៌មានក្នុងស្រុក និងអន្តរជាតិ បន្ទាប់ពីបណ្ដឹងសាទុក្ខត្រូវបានដាក់ជូនទៅផ្នែកគ្រប់គ្រងតុលាការនៃ អ.វ.ត.ក។ ដើម្បីជួយដល់អង្គជំនុំជម្រះនេះ ប្រសិនបើអង្គជំនុំជម្រះសម្រេចទទួលយកសំណើរបស់ ក.ស.ព នោះ មេធាវីការពារក្ដីអាចបង្ហាញនូវការទាក់ទងតាមសារអេឡិចត្រូនិករវាងមេធាវីការពារក្ដី និងបណ្ដាញសារព័ត៌មានទាំងនោះបាន។

៧. ជាងនេះទៀត ប្រសិនបើមានការចាំបាច់ មេធាវីការពារក្ដីក៏ត្រៀមខ្លួនជាស្រេចក្នុងការបង្ហាញជូនទៅអង្គជំនុំជម្រះតុលាការកំពូលថា សកម្មភាពរបស់មេធាវីការពារក្ដីមិនត្រឹមតែស្របទៅនឹងច្បាប់ និងនីតិវិធីនៅកម្ពុជាជាធរមាន ដែលសេចក្ដីណែនាំអនុវត្តនៅ អ.វ.ត.ក មិនមែនជាផ្នែកណាមួយនៃច្បាប់ និងនិតិវិធីនៅកម្ពុជាទេនោះ តែសកម្មភាពទាំងនេះថែមទាំងត្រូវបានរៀបចំឡើង ដើម្បីលើកស្ទួយដល់ផលប្រយោជន៍យុត្តិធម៌នៅតុលាការនេះ និងការពារសិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទផងដែរ។ ការអះអាងដោយមិនត្រឹមត្រូវអំពីភាពសម្ងាត់ផ្នែកវិជ្ជាជីវៈកំពុងត្រូវបានយកមកប្រើខុស ដើម្បីលាក់បាំងពីការពិតដែលគួរឱ្យអាម៉ាស់ និងសភាពជាក់ស្ដែងដែលមិនគួរឱ្យពេញចិត្តអំពីតុលាការនេះ។ ជាការលើសពីការរំលោភបំពានអំណាចឆន្ទានុសិទ្ធិទៅទៀត "ការបិទបាំង" ផ្នែកតុលាការបែបនេះ ជាការរំលោភបំពានអំណាចទាំងស្រុង។ អាស្រ័យហេតុនេះ មេធាវីការពារក្ដីនឹងបន្តផ្សព្វផ្សាយអំណះអំណាងរបស់ខ្លួនជាសាធារណៈ នៅពេលដែលសកម្មភាពបែបនេះស្របទៅនឹងច្បាប់ជាធរមាននៅកម្ពុជា និងផលប្រយោជន៍របស់លោក នួន ជា។

## III.សេចក្ដីសន្និដ្ឋាន

៨. ដោយមានមូលដ្ឋានទៅលើសំអាងហេតុនានានៅក្នុងបណ្ដឹងសាទុក្ខ រួមទាំងសំអាងហេតុនានាដែលបានលើកឡើងនាពេលនេះផងដែរនោះ អង្គជំនុំជម្រះតុលាការកំពូលគួរទទួលយកតាមសំណូមពរដែលបានស្នើឡើងនៅក្នុងបណ្ដឹងសាទុក្ខឱ្យបានឆាប់។ ដូចដែលបានកត់សម្គាល់ពីមុន ជាការត្រឹមត្រូវ គួរមានការបង្ហាញទឡ្ហីករណ៍ផ្ទាល់មាត់នៅក្នុងសវនាការសាធារណៈមួយ មុននឹងធ្វើការសម្រេចសេចក្ដីណាមួយ។

**សហមេធាវីការពារក្ដីលោក នួន ជា**

សុន អារុណ Michiel PESTMAN & Victor KOPPE